ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:...០៥៣...ប្រ.ក....ប.ស្ថ

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ២ .-**

ទម្រង់នៃរូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ គឺមានរាងខែល ដែលមានសេចក្តីបរិយាយ និងខ្លឹមសារដូចខាងក្រោម៖



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

- **ផ្នែកទី១.** ជាស្រទាប់ផ្នែកខាងក្រៅមានផ្ទៃពណ៌បៃតង ព័ទ្ធជុំវិញដោយគំនូសខ្សែពណ៌មាស (លឿង) ដែលមានគំនូសខ្សែខាងក្រៅមានទំហំតូចជាងគំនូសខ្សែខាងក្នុង។ នៅផ្ទៃផ្នែកខាងលើចំកណ្តាលមានរំលេចអក្សរ "**ក្រសួងបរិស្ថាន**" ពណ៌ស និងផ្ទៃផ្នែកខាងក្រោមចំកណ្តាលមានរំលេចអក្សរ "**អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន**" ពណ៌ស។ នៅផ្ទៃផ្នែកចំហៀងទាំងសងខាង មានរូបសញ្ញាព្រះខ័នពណ៌មាស(លឿង) ដែលតំណាងឱ្យការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត លើកិច្ចការគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិ សម្រាប់មន្ត្រីដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌។
- **ផ្នែកទី២.** ជាស្រទាប់ផ្នែកខាងក្នុងមានរាងខែល និងមានរូបផ្សេងៗគ្នាទៅតាមតំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ ដែលមានបាំងខ្លែងពណ៌មាសនៅគ្របពីលើ តំណាងឱ្យបេតិកភណ្ឌវប្បធម៌និងធម្មជាតិ។

សេចក្តីបរិយាយ និងខ្លឹមសារផ្នែកខាងក្នុងនៃតំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

**ប្រការ៣ .-**

រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ ត្រូវបានប្រើប្រាស់ជាផ្លូវការដូចខាងក្រោម៖
- ដាក់នៅផ្នែកខាងលើនៃលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការចេញដោយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ឬអង្គភាពក្រោមឱវាទ
- ប្រើប្រាស់ក្នុងពិធីនានារបស់អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ឬអង្គភាពក្រោមឱវាទ
- ប្រើប្រាស់នៅលើឯកសណ្ឋានមន្ត្រីនៃតំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ
- ប្រើប្រាស់ក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ១៤កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

**សាយ សំអាល់**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ១ នៃប្រកាស លេខ ០៥៣ ប្រ.ក

**ចុះថ្ងៃ ពុធ ១ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**

**ត្រូវនឹងថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២២**

## ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ

១.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ

២.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំយ៉ាត
មន្ទីរបរិស្ថាន ខេត្តប៉ៃលិន

៣.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំង
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

៤.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំគិរីយ៉ង់
មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

៥.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំប្រាំពីរ
មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

៦.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំង
មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

៧.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ
ភ្នំព្រះនេត្រព្រះ
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

៨.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ
ភ្នំព្រះ-ភ្នំខែង
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

៩.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំ
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

១០.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំបាក់
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

១១.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិភ្នំស្វាយ
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

១២.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ
ភ្នំព្រះគុហាល្ហួង
មន្ទីរបរិស្ថាន ខេត្តកំពត

១៣.រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិ
ភ្នំទទុង-ភ្នំតូច
មន្ទីរបរិស្ថាន ខេត្តកំពត

**ឧបសម្ព័ន្ធ២ នៃប្រកាសលេខ ០៥៣ ប្រក**

**ចុះថ្ងៃ ៣ ខ្ទង់ ១ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**

**ត្រូវនឹងថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២២**

**ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ**

## ការបរិយាយ និងខ្លឹមសារ រូបសញ្ញាសម្គាល់តំបន់បេតិកភណ្ឌធម្មជាតិនីមួយៗ

| ល.រ | ឈ្មោះតំបន់ | បរិយាយ និងខ្លឹមសាររូបសញ្ញាសម្គាល់ |
|---|---|---|
| ១. | ភ្នំត្បែង<br>ភូមិសាស្ត្រខេត្តព្រះវិហារ | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះវិហារ<br>១.រូបសញ្ញាវត្តនៅលើភ្នំជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង និងមានរូបសំណាកសត្វគោនៅសងខាងផ្លូវ ព្រមទាំងមានធនធានធម្មជាតិនិងជីវៈចម្រុះសម្បូរបែប។<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងមានសារៈសំខាន់ និងមានតម្លៃផ្នែកជំនឿនិងវប្បធម៌ ពីសិលាចារឹកK៧២៥ នៅលើថ្មកំរើក និងសិលាចារឹក K៧២៦ នៅលើថ្មហោះ(ភាសាសំស្ក្រឹតនៅចុងសតវត្សរ៍ទី៩ និងដើមសតវត្សរ៍ទី១០)និងមានអក្សរបុរាណនៅពើងតាបស់។ លើសពីនេះទៀត មានរូបចម្លាក់បុរាណរូបរាងផ្កាឈូកស្ថិតនៅពើងព្រះច័ន្ទ ខាងក្រោមទីសក្ការៈថ្មបីដុំក្នុងបរិវេណវត្តថ្មបីដុំ និងចម្លាក់បុរាណរូបព្រះពុទ្ធប្រក់នាគស្ថិតនៅពើងតាបស់។ ទីកន្លែងសក្ការបូជារបស់ជនជាតិដើមភាគតិចកួយ ដែលគោរពតពីដូនតាជាច្រើនជំនាន់មកហើយ គឺមានអាស្រមស្ថិតនៅក្នុងវត្តដំបូកខ្មៅ មានថ្មបីដុំស្ថិតនៅក្នុងវត្តថ្មបីដុំ មានពើងព្រះពុទ្ធស្ថិតនៅពីក្រោមវត្តពើងព្រះពុទ្ធ ឬហៅវត្តមហាទេវៈ មហាទេវី និងគោរពតពីដូនតាជាច្រើនជំនាន់មកហើយនៅពើងល្អាងកួយស្ថិតនៅវត្តល្អាងកួយ។<br>ជាមួយគ្នានេះដែរ មានរូបសំណាកព្រះមុន្នីឥស្សីជតិនៅជណ្តើរឡើងលើភ្នំ និងលោកតាសួងនៅពើងតាំងយូរទឹកធ្លាក់៥កន្លែង និងពើងឬល្អាង៩កន្លែង។ |

| | | |
|---|---|---|
| | | ៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងមានសារៈសំខាន់ និងតម្លៃផ្នែកធនធានធម្មជាតិនិងជីវៈចម្រុះសម្បូរបែបដូចជា ព្រៃឈើ និងសត្វព្រៃ និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងអភិរក្សសម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ លើសពីនេះទៀត សារៈសំខាន់និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ក៏មានផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ២. | **ភ្នំយ៉ាត**<br>ភូមិសាស្ត្រខេត្តប៉ៃលិន | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំយ៉ាត និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តប៉ៃលិន<br>១.រូបលោកយាយយ៉ាត និងព្រះចេតិយអង្គចូឡាមណីជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំយ៉ាត។<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំយ៉ាតមានរូបសំណាកលោកយាយយ៉ាត ព្រះវិហារវត្តភ្នំយ៉ាត ព្រះអង្គអភយមុទ្រា និងប្រាសាទប្រាំបីទិស ជណ្ដើរឡើងភ្នំយ៉ាត និងធម្មជាតិដ៏វិសេសវិសាល ដែលសម្បូរទៅដោយរតនសម្បត្តិមានត្បូងនិងផ្សេងៗទៀត ដែលជាអត្តសញ្ញាណខេត្តប៉ៃលិន ព្រមទាំងមានព្រៃឈើនិងសត្វស្លាបរស់នៅ។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំយ៉ាតមានសារៈសំខាន់ និងតម្លៃផ្នែកជីវៈចម្រុះនិងធនធានធម្មជាតិ តម្លៃផ្នែកអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងតម្លៃផ្នែកធនធានវប្បធម៌សម្រាប់ជាឧត្តមប្រយោជន៍របស់មនុស្សគ្រប់ជំនាន់។ បន្ថែមពីនេះទៀត តំបន់បេតិកភណ្ឌធម្មជាតិភ្នំយ៉ាត ក៏មានតម្លៃផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងជំនឿ។ តម្លៃផ្នែកផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៣. | **ភ្នំជញ្ជាំង** | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំង និងនៅផ្នែកខាងក្រោមមានរំលេចអក្សរ |

| | | |
|---|---|---|
| | ភូមិសាស្ត្រ<br>ខេត្តបន្ទាយមានជ័យ | មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១.រូបព្រះអង្គទ្រង់ប្រោសសត្វជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំង និងជាទីកន្លែងសក្ការបូជានិងស័ក្តិសិទ្ធិ។<br>២.មានថ្មភ្នំមានលក្ខណៈហាក់ដូចជាជញ្ជាំងនិងរូងភ្នំថ្ម ដោយមានសត្វប្រចៀវរស់នៅជាច្រើននិងមានប្រភេទសត្វព្រៃ ដូចជា សំពោច កំប្រុក ក្អែក មាន់ព្រៃ ដុំដោរ លលក អែអូត និងមានប្រភេទដើមឈើប្រណិតដូចជា ធ្នង់ កកោះ និងប្រភេទឈើជាច្រើនទៀត។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំងមានសារៈសំខាន់ និងតម្លៃផ្នែកជីវៈចម្រុះនិងធនធានធម្មជាតិដូចជា ប្រភេទថ្មកំបោរ មានសំណាកផូស៊ីលសត្វសមុទ្រ(៥៧០លាន-២២០លានឆ្នាំមុន) និងសារធាតុផ្សេងៗ និងតម្លៃផ្នែកធនធានវប្បធម៌សម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់។ លើសពីនេះទៀត តំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំង ក៏មានតម្លៃផ្នែកសោភ័ណភាពទេសភាពធម្មជាតិ និងតម្លៃធម្មជាតិសម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងជំនឿ តម្លៃផ្នែកផ្តល់សេវាកម្មធម្មជាតិនិងផ្នែកវប្បធម៌សម្រាប់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិ និងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនឹងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៤. | **គិរីយ៉ង់**<br>ភូមិសាស្ត្រខេត្តបាត់ដំបង | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិគិរីយ៉ង់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបាត់ដំបង<br>១.មានរូបភ្នំដែលមានសណ្ឋានដូចសត្វដំរីដេក ជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិគិរីយង់ ធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែប។<br>២.ក្រុមការងារស្រាវជ្រាវប្រវត្តិសាស្ត្រ ដែលបានសិក្សានៅល្អាងស្ពាននៃភ្នំទាក់ទ្រាំង បានបន្តធ្វើការស្រាវជ្រាវ(កំណាយ)នៅភ្នំគិរីយង់លើកដំបូងដោយមិនចាំឆ្នាំ បានរកឃើញនូវពូថៅធ្វើពីថ្មរំលីង និងកម្ទេចកម្ទីនៃកុលាលភាជន៍ប្រមាណជាង១០ដុំ។ ក្រុមការងារបានសន្និដ្ឋានថា មានមនុស្សសម័យបុរាណកាលពី៣០០០ឆ្នាំមុន បានមករស់នៅក្នុងល្អាងទូកនៃភ្នំគិរីយង់ និង |

| | | |
|---|---|---|
| | | ដើរបរបាញ់សត្វធ្វើជាអាហារ។<br>៣.មានល្អាងនិងរូងភ្នំដ៏ធំ ដោយមានសត្វប្រចៀវរស់នៅរាប់ម៉ឺនក្បាល និងប្រភេទសត្វព្រៃដូចជា ពពែភ្នំ ឈ្លូស ជ្រូកព្រៃ ប្រមាសំពោច ក្តាន់ព្រៃង ទោច ស្វា ក្ងោក មាន់ព្រៃ និងសត្វស្លាបជាច្រើនទៀត។ មានប្រភេទឈើដូចជា បេង ធ្នង់ ម្រះព្រៅ កកោះ ធ្វឹក ខ្វាវ សុក្រំ និងដើមឈើតូចធំចម្រុះជាច្រើន។<br>៤.ជាភ្នំមានប្រភេទថ្មកំបោរ ដែលមានប្រភពទឹកចេញពីបាតល្អាង មានអូរមួយដែលមានក្បាលទឹកចេញពីភ្នំគិរីយ៉ង់ ដោយមិនចេះរីងស្ងួតខួបប្រាំងនិងវស្សា សម្រាប់ប្រជាជនប្រើប្រាស់។<br>៥.តំបន់បេតិកភណ្ឌធម្មជាតិគិរីយ៉ង់មានសារៈសំខាន់ និងតម្លៃផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាឧត្តមប្រយោជន៍របស់មនុស្សគ្រប់ជំនាន់។ បន្ថែមពីនេះទៀត តំបន់បេតិកភណ្ឌធម្មជាតិគិរីយ៉ង់ ក៏មានតម្លៃផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងជំនឿ។ តម្លៃផ្នែកផ្តល់សេវាកម្មធម្មជាតិនិងផ្នែកវប្បធម៌ សម្រាប់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារនិងអភិរក្សធនធានធម្មជាតិ នឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៥. | **ភ្នំប្រាំពីរ**<br>ភូមិសាស្ត្រខេត្តបាត់ដំបង | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំប្រាំពីរ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបាត់ដំបង<br>១.រូបលោកយាយសំជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំប្រាំពីរ និងមាននាគមួយគូមានឥទ្ធិពលដ៏ស័ក្តិសិទ្ធិ និងមានរូបព្រះពុទ្ធបដិមាមួយដ៏ធំដែលទើបសាង់សង់នៅចង្កេះភ្នំដើម្បីគោរពបូជា។<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំប្រាំពីរមានសត្វទោច(សប្បុរខ្មៅ) ស្វា ពពែភ្នំ ឈ្លូស ប្រមា ពស់ថ្លាន់ ពស់វែកនាម កំប្រុកមាន់ព្រៃ ប្រចៀវ សារិកាកែវ ជាដើម និងមានប្រភេទដើមឈើរួមមាន បេង ធ្នង់ ម្រះព្រៅ ខ្វាវ ស្លង់ រកា សុក្រំ ច័ន្ទធូត ប្រទាលជ្រៃ ផ្តៅស្រែងជាដើម ព្រមទាំងជាភ្នំដែលមានសិលា (ថ្មកែវ ថ្មថ្លើមអណ្តើក ថ្មក្រានីត និងថ្មកំបោរ)។<br>៣. តំបន់បេតិកភណ្ឌធម្មជាតិភ្នំប្រាំពីរមានសារៈសំខាន់ និងតម្លៃផ្នែកធនធានធម្មជាតិនិងជីវៈចម្រុះដូចជា ព្រៃឈើ និងសត្វព្រៃ |

| | | |
|---|---|---|
| | | និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងអភិរក្ស សម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ ជាងនេះទៀត សារៈសំខាន់និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំប្រាំពីរ ក៏មានផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារនិងអភិរក្សធនធានធម្មជាតិ នឹងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៦. | **ភ្នំទាក់ទ្រាំង**<br>ភូមិសាស្ត្រខេត្តបាត់ដំបង | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបាត់ដំបង<br>១.រូបភ្នំនិងរូបល្អាងថ្ម(ល្អាងស្ពានថ្ម)នៅចំកណ្តាលជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំង និងធនធានធម្មជាតិ។<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំងជាស្ថានីយបុរេប្រវត្តិតែមួយគត់ ដែលមានអាយុកាលចាស់ជាងគេនៅកម្ពុជា។ អ្នកស្រាវជ្រាវបានរកឃើញបំណែកឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្ម និងកម្ទេចកម្ទីកុលាលភាជន៍ទាក់ទងនឹងការតាំងលំនៅក្នុងរូងភ្នំរបស់មនុស្សនៅបីដំណាក់កាលផ្សេងគ្នា៖ សម័យថ្មបំបែក សម័យវប្បធម៌ហាវប៊ីនញៀន និងសម័យថ្មរំលីង។ គេបានរកឃើញផ្នូរបុរាណចំនួនពីរមានអាយុកាលជាង ៣៣០០ឆ្នាំ និងវត្ថុបុរាណជាច្រើននៅជិតផ្នូរដូចជា ផ្តិល កាំបិត ពូថៅធ្វើពីថ្មរំលីង និងថ្មរឹង បំណែកឆ្អឹងសត្វមាស ពពែ ក្តាន់ និងប្រើស ។ ជាមួយគ្នានេះដែរ តំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំងមានល្អាងធំមួយដែលមានសណ្ឋានដូចស្ពាន គេហៅថាល្អាងស្ពាន។ ភ្នំទាំងមូលភាគច្រើនគ្របដណ្តប់ទៅដោយព្រៃឈើដែលជាទីជម្រកសម្រាប់សត្វព្រៃរស់នៅ និងមានផ្ទាំងថ្មធំៗជាច្រើន ដែលជាប្រភេទថ្មកំបោរ។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំងមានសារៈសំខាន់ និងតម្លៃផ្នែកធនធានធម្មជាតិនិងជីវៈចម្រុះដូចជា ព្រៃឈើនិងសត្វព្រៃ និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងអភិរក្សសម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ ជាងនេះទៀត សារៈសំខាន់និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំទាក់ទ្រាំង ក៏មានផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវ |

| | | |
|---|---|---|
| | | វិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៧. | **ភ្នំព្រះនេត្រព្រះ**<br>ភូមិសាស្ត្រ<br>ខេត្តបន្ទាយមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះនេត្រព្រះ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១.រូបស្នាមព្រះបាតរបស់ព្រះពុទ្ធជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះនេត្រព្រះ ដែលនៅលើភ្នំមានគ្រឹះប្រាសាទបុរាណចេតិយបុរាណ និងវត្តអារាមដែលជាទីសក្ការបូជា និងមានធនធានធម្មជាតិ។<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះនេត្រព្រះមានប្រភេទសត្វដូចជា ទន្សាយ កំប្រុក សំពោច ក្អែក ជំងោរ មាន់ព្រៃ លលក អែអូត ស្វា និងដើមឈើរួមមាន ធ្នង់ កកោះ សុក្រំ រកា និងដើមឈើតូចធំចម្រុះជាច្រើន។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះនេត្រព្រះមានសារៈសំខាន់ និងតម្លៃផ្នែកធនធានធម្មជាតិនិងជីវៈចម្រុះដូចជា ព្រៃឈើនិងសត្វព្រៃ និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងអភិរក្សសម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ លើសនេះទៀត សារៈសំខាន់និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះនេត្រព្រះ ក៏មានផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃផ្នែកធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៨. | **ភ្នំព្រះ-ភ្នំវែង**<br>ភូមិសាស្ត្រ<br>ខេត្តបន្ទាយមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១.រូបព្រះអង្គមានព្រះហស្តច្រើនជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង និងមានវត្តអារាម ដោយមានធនធានធម្មជាតិ និងមានជីវៈចម្រុះសម្បូរបែប។<br>២.មានល្អាង មានសត្វប្រចៀវនៅ។ ប្រភេទសត្វព្រៃដូចជា ខ្លាត្រី ឈ្លូស ជ្រូកព្រៃ ប្រមា ស្វា ទន្សាយ គ្រលីងគ្រលោង ក្អែក ជំងោរ |

| | | |
|---|---|---|
| | | លលក មាន់ព្រៃ សារិកាកែវ អែអូត និងមានប្រភេទដើមឈើ រួមមាន កកោះ បេង សុក្រំ ។ល។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែងមានសារៈសំខាន់និងតម្លៃផ្នែកធនធានធម្មជាតិដូចជា ថ្មកំបោរនិងសារធាតុផ្សេងទៀត ដែលមិនទាន់បានសិក្សាស្រាវជ្រាវ និងជីវៈចម្រុះ ដូចជា ព្រៃឈើនិងសត្វព្រៃ និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងអភិរក្ស សម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ លើសពីនេះទៀត សារៈសំខាន់និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង ក៏មានផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃផ្នែកធម្មជាតិសម្រាប់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៩. | **ភ្នំយាយសំ**<br>ភូមិសាស្ត្រ<br>ខេត្តបន្ទាយមានជ័យ | នៅខាងក្នុងនៃរូបសញ្ញា ផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១.មានរូបសំណាកយាយសំជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំ និងធនធានធម្មជាតិព័ទ្ធជុំវិញ។<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំមានរូងសត្វប្រចៀវ និងគ្របដណ្តប់ដោយព្រៃឈើដែលជាទីជម្រកសម្រាប់សត្វព្រៃមួយចំនួនរស់នៅ។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំមានសារៈសំខាន់និងតម្លៃផ្នែកធនធានធម្មជាតិ និងជីវៈចម្រុះ ដូចជា ព្រៃឈើនិងសត្វព្រៃ និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងការអភិរក្សសម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ ជាងនេះទៀត សារៈសំខាន់និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំ ក៏មានផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១០. | **ភ្នំបាក់** | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំបាក់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរ |

| | | |
|---|---|---|
| | ភូមិសាស្ត្រ<br>ខេត្តបន្ទាយមានជ័យ | បរិស្ថានខេត្តបន្ទាយមានជ័យ<br>១.រូបប្រហោងរូងភ្នំបាក់ជាតំណាងបេតិកភណ្ឌធម្មជាតិភ្នំបាក់ វត្តអារាម និងធនធានធម្មជាតិ<br>២.តំបន់បេតិកភណ្ឌធម្មជាតិភ្នំបាក់ មានដើមឈើច្រើនជាពិសេសប្រភេទឈើក្រញូង ព្រមទាំងមានវត្តមានសត្វព្រៃនិងមានរូងប្រចៀវ។ តាមការសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានតំបន់បេតិកភណ្ឌនៃក្រសួងបរិស្ថាន បានរកឃើញនូវសំណាកផូស៊ីលផ្សេងៗនៅក្នុងតំបន់នេះ។ តំបន់នេះមានទេសភាពស្អាតនៅពេលដែលយើងឡើងទៅមើលពីលើកំពូលភ្នំ ហើយគេអាចគយគន់ព្រះអាទិត្យអស្តង្គត និងមើលឃើញក្រុងសិរីសោភ័ណបានផងដែរ ជាពិសេសមានល្អាងដែលភ្ញៀវទេសចរអាចចូលលេងកម្សាន្តបានប្រកបដោយសុវត្ថិភាពថែមទៀតផង។<br>៣.តំបន់បេតិកភណ្ឌធម្មជាតិភ្នំបាក់មានសារៈសំខាន់ និងតម្លៃផ្នែកធនធានធម្មជាតិនិងជីវៈចម្រុះ ដូចជា ព្រៃឈើនិងសត្វព្រៃ និងផ្នែកប្រព័ន្ធអេកូឡូស៊ី ព្រមទាំងតម្លៃផ្នែកជំនឿនិងវប្បធម៌ ដែលត្រូវរួមគ្នាគ្រប់គ្រង ការពារ និងអភិរក្សសម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ បន្ថែមនេះទៀត សារៈសំខាន់ និងតម្លៃរបស់តំបន់បេតិកភណ្ឌធម្មជាតិភ្នំបាក់ ក៏មានតម្លៃផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងតម្លៃផ្នែករក្សានូវលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១១. | **ភ្នំស្វាយ**<br>ភូមិសាស្ត្រ<br>ខេត្តបន្ទាយមានជ័យ | នៅខាងក្នុងនៃរូបសញ្ញា ផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំស្វាយ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១. រូបភ្នំស្វាយជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំស្វាយ និងសំណង់ចេតីយបុរាណតាំងពីសម័យសង្គមរាស្ត្រនិយម។<br>២.តំបន់បេតិកភ័ណធម្មជាតិភ្នំស្វាយមានសារៈសំខាន់ និងតម្លៃផ្នែកធនធានធម្មជាតិនិងជីវៈចម្រុះ ដូចជាព្រៃឈើនិងសត្វព្រៃ និងតម្លៃផ្នែកប្រព័ន្ធអេកូឡូស៊ី សម្រាប់ជាប្រយោជន៍មនុស្សគ្រប់ជំនាន់។ ជាងនេះទៀត តំបន់បេតិកភណ្ឌធម្មជាតិភ្នំស្វាយ ក៏មានតម្លៃផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃផ្នែកធនធានធម្មជាតិ សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការ |

| | | |
|---|---|---|
| | | អប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងជំនឿ ផ្តល់សេវាកម្មធម្មជាតិនិងវប្បធម៌ និងតម្លៃផ្នែករក្សានូវលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១២. | **ភ្នំព្រះគុហារហ្លួង**<br>ភូមិសាស្ត្រខេត្តកំពត | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះគុហារហ្លួង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពត<br>១. រូបសត្វប្រចៀវនិងភ្នំ ជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះគុហារហ្លួង និងធនធានធម្មជាតិសំបូរបែប។<br>២. ជាតំបន់មានទេសភាពស្រស់ស្អាត មានរូងភ្នំ និងផ្ទាំងថ្មសម្រាប់បម្រើវិស័យទេសចរណ៍ធម្មជាតិ។<br>៣. ជាទីតាំងដែលមានសិលាចារិក K44 ចារនៅសតវត្សទី៧ ក្នុងរាជ្ជកាលព្រះបាទជ័យវរ្ម័ទី១។ ល្អាងភ្នំព្រះគុហារហ្លួង ឬល្អាងប្រចៀវស្ថិតក្នុងភ្នំទូកមាសខាងកើត គឺជាទីតាំងបុរាណដែលបានចុះក្នុងបញ្ជីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។<br>៤. ជាជម្រកសត្វប្រចៀវដែលសហគមន៍បានការពារដើម្បីប្រមូលអាចម៍ប្រើប្រាស់ធ្វើជី និងលក់ផ្គត់ផ្គង់ជីវភាព ចាប់តាំងពីសម័យសង្គមរាស្ត្រនិយម។ ចាប់ពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្នមានការបង្កើតជាក្រុមប្រមូលទិញអាចម៍ប្រចៀវ ដោយបង្កើតជាខ្សែរ៉ែកដឹកជញ្ជូនពីកំពូលភ្នំមកក្រោម និងមានភ្នាក់ងារយាមការពារសត្វ។ កិច្ចការថែរក្សាសត្វប្រចៀវមានការឯកភាពនៅកម្រិតថ្នាក់ស្រុក(បន្ទាយមាស)។<br>៥.តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះគុហារហ្លួង មានសារៈសំខាន់និងមានតម្លៃផ្នែកប្រព័ន្ធអេកូឡូស៊ី សម្រាប់ជាប្រយោជន៍មនុស្សគ្រប់ជំនាន់។ ជាងនេះទៀត វាក៏មានតម្លៃផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃផ្នែកធនធានធម្មជាតិ សម្រាប់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ជំនឿនិងវប្បធម៌ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយ។ |
| ១៣. | **ភ្នំទទុង-ភ្នំតូច**<br>ភូមិសាស្ត្រខេត្តកំពត | នៅខាងក្នុងនៃរូបសញ្ញាផ្នែកខាងលើមានរំលេចអក្សរតំបន់បេតិកភណ្ឌធម្មជាតិភ្នំទទុង-ភ្នំតូច និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពត<br>១.រូបប្រាសាទនៅក្នុងល្អាងភ្នំនិងភ្នំជាតំណាងតំបន់បេតិកភណ្ឌធម្មជាតិភ្នំទទុង-ភ្នំតូច និងមានធនធានធម្មជាតិសំបូរបែប<br>២)ក្នុងល្អាងភ្នំ មានប្រាសាទមួយឈ្មោះ «ប្រាសាទភ្នំទទុង» កសាងក្នុងសតវត្សទី៧ នៃគ.ស។ បច្ចុប្បន្ន សរសេរពេជ្រ សិវលិង្គ |

| | | |
|---|---|---|
| | | ព្រះកេស រូបបដិមាឈរជេងខ្លួនត្រឹមស្មាស្តាំនិងជើងទម្រ ភាជនិងចូលោហធាតុរបស់ប្រាសាទត្រូវបានប្រមូលយកទៅរក្សាទុកនៅសារមន្ទីរ និងមន្ទីរវប្បធម៌ខេត្តកំពត។<br>៣.នៅក្បែរភ្នំទទុងមានទីតាំងបុរាណរួមមានៈ ស្រះ ទួល ឡស្លដែក និងឡដុតកំបោរ និងមានផ្លូវទឹកសម្រាប់បម្រើវិស័យទេសចរណ៍វប្បធម៌ និងធម្មជាតិ។<br>៤.តំបន់បេតិកភណ្ឌធម្មជាតិភ្នំទទុង-ភ្នំតូចមានតម្លៃនិងតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាឧត្តមប្រយោជន៍មនុស្សគ្រប់ជំនាន់។ ជាងនេះទៀត តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំទទុង-ភ្នំតូច ក៏មានតម្លៃផ្នែកសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃផ្នែកធនធានធម្មជាតិសម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងជំនឿ ផ្តល់សេវាកម្មធម្មជាតិនិងវប្បធម៌ និងតម្លៃផ្នែករក្សាលំនឹងបរិស្ថាន។ ការការពារ និងអភិរក្សធនធានធម្មជាតិនឹងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |